**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ: ៥០
ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០០៤
សាលដីកា
លេខ: ១៤២
ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម .......... ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក ........... ជាចៅក្រម
៣-លោក ......... ជាចៅក្រមរបាយការណ៍
៤-លោក ............. ជាចៅក្រម
៥-លោក ............. ជាចៅក្រម

ក្រឡាបញ្ជី

-លោក ...............

តំណាងមហាអយ្យការ

-ឯកឧត្តម ............ ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខសាលដីកាលេខ២៣(យ) ចុះថ្ងៃទី២៨ខែមេសា ឆ្នាំ២០០៣នៃសំណុំរឿងរដ្ឋប្បវេណីលេខ៦៤ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍រវាង:

ដើមចោទឈ្មោះ ពប(ជាចុងបណ្តឹងសាទុក្ខ )ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ របររកស៊ី មេបញ្ជាការរង មានទីលំនៅផ្ទះលេខ: ១៩២ ផ្លូវលេខ ១ សង្កាត់បរឌិននៀវ ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន ឳពុកឈ្មោះព្រហ្ម ពុយ (ស) ម្តាយឈ្មោះ ព្រហ្ម លុយ (ស) ។

មានដមេធាវីលោក ............។

និងចុងចម្លើយឈ្មោះ ឆលដ( ជាម្ចាស់បណ្តឹងសុក្ខ ) ភេទស្រី អាយុ២៣ឆ្នាំ ជាតិខ្មែរ របរកស៊ី លក់ខាអាវ មានទីលំនៅ ផ្ទះលេខ: ១៧២E, ផ្លូវលេខ ២១៥ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ឳពុក ឈ្មោះ ឆម ស៊ីណាល់ (ស) ម្តាយឈ្មោះ មុយ សុខជា(ស ) ។

មានមេធាវីលោក ........

**កម្មវត្ថុបណ្តឹង:** ប្តឹងទាមទារប្រាក់។

បានឃើញបណ្តឹងសាទុក្ខលេខ: ២៤៣ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ របស់ឈ្មោះ ឆលដ បានប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខៈ ៥០ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៤ របស់តុលាការកំពូល។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៦-០៦-២០០១ របស់ឈ្មោះ ពបដើមចោទប្តឹងទាមទារប្រាក់ជំពាក់៣៥.០០០ ដុល្លា ពីឈ្មោះ ឆលដ ព្រោះតាមកិច្ចសន្យាចុះថ្ងៃទី០៦-១០-៩៩ លោក ធម ស៊ីណាល់ ដែលជាឪពុក របស់ឈ្មោះ ឆលដ បានខ្ចីប្រាក់ពីខ្លួន៣៥.០០០ដុល្លារយៈពេល០៦ខែ និងគិតការប្រាក់ក្នុង០១ខែ១.៧៥០ដុល្លា ដោយដាក់បញ្ចាំអចលនវត្ថុលេខ ២៩០៤ ចុះថ្ងៃទី១២-០៦-៩១ ។លុះដល់ថ្ងៃទី១៥-០៩-២០០០លោក ធម ស៊ីណាល់ បានទទួលមរណៈភាពដោយពុំទាន់បានឱ្យការប្រាក់និងប្រាក់ដើមមកខ្លួនវិញទេ។ ក្នុងកិច្ចសន្យាចុះថ្ងៃទី០៦-១០-១៩៩៩ ត្រង់ប្រការ៤ មានចែងពីការទទួលខុសត្រូវបន្តពីកិច្ចសន្យា គឺឈ្មោះ ឆលដដែលត្រូវជាកូន។

បានឃើញដីកាសំរេចកិច្ចការប្រញាប់លេខ ០៣(ធ) ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០១ របស់តុលាការ ក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១ – ទទួលស្គាល់សិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៦-០៧-២០០១ ពីឈ្មោះ ពបជូនមេធាវី ............ជាតំណាងទុកជាត្រឹមត្រូវតាមច្បាប់ ។

២ - ទទួលពាក្យបណ្តឹងសុំកិច្ចការប្រញាប់ឃាត់ផ្ទះចុះថ្ងៃទី១៦-០៧-២០០១ របស់មេធាវី ............សំណាងឱ្យឈ្មោះពបជាដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

៣ - ហាមឃាត់ឈ្មោះ ឆលដ ភេទស្រី អាយុ២៣ឆ្នាំ មិនឱ្យលក់ដូរ ផ្ទេរ ជួល បញ្ចាំ ធ្វើអំណោយទៅ ឱ្យអ្នកដទៃផ្លូវផ្ទះលេខ១៧២$AE_0$ ផ្លូវ ២១៥ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ដែលមានវិញ្ញាបនបត្រ័សម្គាល់ម្ចាស់អចលនវត្ថុលេខ ២៩០៤ ចុះថ្ងៃទី២៩-០៥-១៩៩១ របស់នាយកមន្ទីររៀបចំក្រុងសំណង់ក្រុងភ្នំពេញ ទុកជាបណ្តោះអាសន្នរហូតដល់តុលាការសម្រេចដល់រឿងអង្គសេចក្តី ។

៤ - ឱ្យតំណាងដើមចោទបង់ប្រាក់ប្រដាប់ក្តីចំនួន ៤០០០៛ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន ១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ២០០០៛ សរុប ៤០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ ៤០០០៛ ដែលតំណាងដើមចោទបានបង់ទុកជាស្រេច ។

៥ - ដីកាសម្រេចកិច្ចការប្រញាប់នេះ មានអានុភាពអនុវត្តភ្លាមៗ ទោះបីជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

៦-ដីកាសម្រេចនេះ ជំនុំជំរះ ចំពោះមុខគូក្តីបើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ២៦ (ធ) ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០២ របស់តុលាការ ក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ

១ - ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៦-០៦-២០០១ របស់ឈ្មោះ ពបជាដើមចោទទុកជាត្រឹមត្រូវ តាមទម្រង់ និង គតិច្បាប់ ។

២ - ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៦-០៧-២០០១ របស់ឈ្មោះ ពបឱ្យមេធាវី ............ជាតំណាងទុកជាត្រឹមត្រូវតាមច្បាប់ ។

៣- ទុកជាមោឃៈកិច្ចព្រមព្រៀងចុះថ្ងៃទី០៦ខែតុលា ឆ្នាំ១៩៩៩ លិខិតផ្ទេរសិទ្ធិកាន់កាប់ផ្ទះចុះថ្ងៃទី០៦-១០-១៩៩៩ កិច្ចសន្យាចុះថ្ងៃទី០៦-១០-១៩៩៩ របស់លោក ពបលិខិតលក់ផ្ទះចុះថ្ងៃទី០៦-១០-៩៩ កិច្ចសន្យាជួលផ្ទះចុះថ្ងៃទី១៦-១០-១៩៩៩ និង កិច្ចសន្យាលក់ជូនម្ចាស់ដើមវិញចុះថ្ងៃទី០៦-១០-១៩៩៩ ។

៤- បង្គាប់ឱ្យឈ្មោះ ធលដ ជាទាយាទកូនបំណុលសងប្រាក់ដើមចំនួន ៣៥.០០០ $US (បីម៉ឺនប្រាំ ពាន់ដុល្លាអាមេរិក ) សងការប្រាក់៥%ក្នុងមួយឆ្នាំ គិតពីថ្ងៃ០៦-១១-១៩៩៩ រហូតថ្ងៃសងប្រាក់រួច និង ជម្ងឺចិត្តចំនួន ៥០០ ដុល្លាឱ្យទៅឈ្មោះ ពបចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ។

បើចុងចម្លើយមិនព្រមសងត្រូវរឹបអូសផ្ទះដាក់ធានាលេខៈ១៧២AE$_0$ ផ្លូវលេខៈ២១៥សង្កាត់វាលវង់ខណ្ឌ៧មករា ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២៩០៤ចុះថ្ងៃទី១២-០៦-៩១ ចេញដោយគណកម្មាធិការប្រជាជនរដ្ឋជានីភ្នំពេញលក់ឡាយឡុងជានាសំណង ។

៥ - ឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ ហិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០៛ សរុប ៧.០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ ដែលតំណាងដើមចោទបានបង់ទុករួចជាស្រេច ។

កាលបើហួសឧទ្ធរណ៍បង្គាប់ឱ្យចុងចម្លើយសងប្រាក់ ៧.០០០៛ ទៅដើមចោទវិញ និងបង់ពន្ធសមាមាត្រចំនួន ១% លើប្រាក់ត្រូវសងទាំងអស់។ប្រាក់ពន្ធសមាមាត្រនេះ បង់ចូលថវិការដ្ឋចំនួន៨០% និងបានជារង្វាន់ ក្រឡាបញ្ជីទូទាំងប្រទេសចំនួន ២% ។

៦- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តីបើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៧(ធ)ចុះថ្ងៃទី២០ខែកញ្ញា ឆ្នាំ២០០២ របស់ឈ្មោះ ធលដ និងបណ្តឹងឧទ្ធរណ៍លេខ១៨ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០២ របស់លោក ............ជាមេធាវីការពារឱ្យលោក ពបបានប្តឹងមិនសុខចិត្តនឹងសាលក្រមរបស់តុលាការក្រុងភ្នំពេញត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលខ២៣(ឃ)។ ចុះថ្ងៃ៖២៨ ខែមេសា ឆ្នាំ២០០៣របស់សាលឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២០-០៩-២០០២របស់ឈ្មោះធលដ និងដើមបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៣-០៩-២០០២ របស់ឈ្មោះ ............ជាមេធាវីតំណាងដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ២៦( ធ) ចុះថ្ងៃទី២៥-០៧-២០០២ របស់តុលាការក្រុងភ្នំពេញ ទុកជាជានការ ។

៣ - កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ២៦.០០០៛ ដែលដើមចោទបានចង់ជួស គឺ ពន្ធចុះបញ្ជីក្តី ពន្ធហ្នឹង៥១០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៩០០៛ ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ១០០០០៛ និង ចំណាយលើអាជ្ញាធរតុលាការ ១០០០០៛។

បង្គាប់ឱ្យចុងចម្លើយឈ្មោះ ធលដ សងប្រាក់ប្រដាប់ក្តីចំនួន ១៣០០០៛ ទៅឱ្យដើមចោទីវិញ ។

៤ - សាលដីកានេះ ជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខគួភាគីបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

បានឃើញ បណ្តឹងសាទុក្ខលេខៈ ២៤៣ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ របស់ឈ្មោះ ធលដ បានប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញ សារណារបស់ឈ្មោះ ធលដ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៤ ។

បានឃើញសារណាឆ្លើយតបរបស់ឈ្មោះ ពបចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៤ ។

បានស្តាប់របាយការណ៏របស់ចៅក្រមរបាយការណ៏

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : បណ្តឹងសាទុក្ខរបស់អ្នកស្រី ធមលីនដា ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិចារណា ។

សាលាឧទ្ធរណ៍សម្រេចសេចក្តីមកនេះត្រឹមត្រូវហើយ ។

សូមក្រុមប្រឹក្សា ជំនុំជំរះ សម្រេចតាមច្បាប់ ។

អ្នកស្រី ធលដ បានឆ្លើយថា : មិនសុខចិត្តត្រង់ចំណុចដែលឪពុកខ្លួនបានខ្ចីប្រាក់លោក ពបតែ

ឪពុកខ្លួនគ្រាន់តែជាអ្នកដាក់ប្លង់ដើម្បីជានាតែប៉ុណ្ណោះ ចំណែកប្រាក់គឺឈ្មោះណា វ៉ាន់នី ជាអ្នកយកទៅប្រើប្រាស់ ទាំងអស់ ហើយបែរជាសម្រេចមកឱ្យខ្លួនសងទៅឈ្មោះពបទៅវិញត្រង់នេះហើយផ្ទុយទៅនឹងច្បាប់ទាំងស្រុង។

សំណូមពរៈ ខ្លួនសុំឱ្យឯកឧត្តម មេត្តាបញ្ចូលឈ្មោះ ណាវ៉ាន់នី មកចូលក្នុងរឿងក្តីនេះផង និងសុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោលទាំងអស់ ។

ក្រឡាបញ្ជីអានសារណារបស់ឈ្មោះ ពប។

មេធាវីលោក ........ការពារឱ្យអ្នកស្រី ធមលីនដា បានធ្វើសេចក្តីសន្និដ្ឋានថា ឯកសារទាំងអស់ដែលមានក្នុងសំណុំរឿងនេះគឺជាការដាក់បន្ទុកយ៉ាងធ្ងន់ធ្ងរមកលើកូនក្តីរបស់ខ្លួនហើយៗក៏ជាការកេងបន្លំយកចំណេញពីកូនក្តីរបស់ខ្លួនទាំងស្រុង សូមឯកឧត្តមមេត្តាពិចារណាលើចំណុចទាំងនេះឱ្យបានច្បាស់។

ឪពុករបស់កូនក្តីខ្លួនគាត់គ្រាន់តែជាអ្នកដាក់ប្លង់ដើម្បីជានាតែប៉ុណ្ណោះ ឯប្រាក់វិញគឺឈ្មោះ ណាវ៉ាន់នី ជាអ្នកយក ហើយបែរជាសម្រេចមកឱ្យកូនក្តីរបស់ខ្លួនសងវិញត្រង់នេះផ្ទុយទៅនឹងមាត្រា ១១៦នៃច្បាប់លេខ ៣៨ ស្តីពី កិច្ចសន្យា និង ការទទួលខុសត្រូវក្រៅតិច្ចសន្យា ។

នៅតុលាការក្រុងត្រង់ចំណុចទី៦ បានបញ្ជាក់ថា ដើមចោទបានទទួលប្រាក់ចំនួនមួយពាន់ដុល្លា តាមលិខិតចុះថ្ងៃទី១៤ -០៣-២០០០ ហើយចុងចម្លើយក៏ពុំទាមទារការប្រាក់នេះក្នុងបំណុលដើមដែរ នោះតុកលាកាពុំបានលើកយកមកពិចារណាឡើយ ។

ការជំពាក់ប្រាក់គឺនៅក្នុងកិច្ចសន្យាចុះថ្ងៃទី១៦-១០-១៩៩៩ នៃការប្តឹងឱ្យអនុវត្តនេះគឺមានភាពមិនប្រក្រតីឡើយ សូមឯឧត្តមមេត្តាពិចារណា ។

សំណូមពរៈ សុំបញ្ចូលឈ្មោះ ណាវ៉ាន់នី ក្នុងសំណុំរឿងក្តីផង ដើម្បីបញ្ជាក់ពីភាពយុត្តិធមិដល់កូនក្តីរបស់ខ្លួន និង បដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោលទាំងមូល ដោយបង្វិលសំណុំរឿងនេះទៅឱ្យសាលាឧទ្ធរណ៍ដើម្បី ឱ្យសាលាឧទ្ធរណ៍សម្រេចជាថ្មីឡើងវិញ ។

មេធាវីលោក ............ការពារឱ្យលោក ពបបានធ្វើសេចក្តីសន្និដ្ឋានថា

.តាមកិច្ចសន្យខ្ចីប្រាក់ចុះថ្ងៃទី០៦-២០-៩៩ ដែលមានលោកធម ស៊ីណាល់ មកខ្ចីដោយផ្ទាល់ហើយបានដាក់បញ្ចាំវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២៩០៤ ចុះថ្ងៃទី១២-០៦-៩១ គឺជាការខ្ចីដោយមានការព្រមព្រៀងគ្នាមិនបង្ខំបោកប្រាស់ គឺដោយសុចរិតទៀងត្រង់ ព្រោះនៅលើកិច្ចសន្យានេះ គូភាគីនៃកិច្ចសន្យាបានផ្តិតមេដៃទទួលស្គាល់ហើយមានទាំងសាក្សីដឹងឮទៀតផង មិនតែប៉ុណ្ណោះគាត់បានឱ្យកូនឈ្មោះ ធលដ ទទួលខុសត្រូវបំពេញកាតព្វកិច្ចបន្តពីគាត់ទៀតដោយបានផ្តិតមេដៃ នៅលើកិច្ចសន្យានេះដែរ ។ ក្រោយមកលោក ធម ស៊ីណាល់ទទួលមរណៈភាព គឺកាតព្វកិច្ចត្រូវធ្លាក់មកលើទាយាទតាមច្បាប់ ព្រោះអាជ្ញាយុកាលនៃបណ្តឹងមិនត្រូវបានថ្លោះសិទ្ធិដូចពាក្យដែលគេបានលើកឡើងឡើយ ។

ចំណែកឯការប្រាក់កូនក្តីរបស់ខ្លួនមិនបានទទួលពីគាត់ម្តងណាឡើយ ម៉្យាងទៀតគាត់ថា បានប្រគល់ភាប្រាក់ទៅឱ្យអ្នកស្រី ប៉ិច រដ្ឋីរក្ស គឺជាការមិនត្រឹមត្រូវឡើយ គឺមិនមានភារកិច្ចទទួលយកប្រាក់ពីលោក ធម ស៊ីណាល់ឡើយ ព្រោះគាត់គ្រាន់តែជាសាក្សីប៉ុណ្ណោះ ពិសេសអ្នកស្រី ប៉ិច រដ្ឋីរក្ស បានបដិសេធថាគាត់មិនបានទទួលប្រាក់ពី ឈ្មោះ ធម ស៊ីណាល់ ម្តងណាឡើយ ។

. បើបញ្ចូលឈ្មោះ ណា វ៉ាន់នី ចូលក្នុងរឿងក្តីនេះ គឺជាការខុសច្បាប់ ព្រោះនៅក្នុងកិច្ចសន្យាមិនមានជាប់ ពាក់ពន្ធ័និងឈ្មោះនេះឡើយ ។

សំណូមពរៈ សុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៏ទុកជាបានការដដែល ។

- ក្រោយពីបានស្តាប់របាយការណ៏របស់ចៅក្រមរបាយការណ៏

- ក្រោយពីបានស្លាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអាយ្យការ

- ក្រោយពីបានស្តាប់ចម្លើយរបស់តំណាងចុងចម្លើយ សារណាការពាររបស់ដើមចោទ និង សេចក្តីសន្និដ្ឋានរបស់នៃមេធាវីគូភាគី

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៤៣ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ របស់អ្នកស្រី ធលដ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមក ជំនុំជំរះ បានតាមមាត្រា ១៤ នៃច្បាច់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

យល់ឃើញថាៈ តាមកំណត់ហេតុយកចម្លើយចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០២ នៅតុលាការក្រុងភ្នំពេញអ្នកស្រី ធលដ បញ្ជាក់ថាលោក ធម ស៊ីណាល់ ឬ ធម តាំងខ្លួនបានទទួលមរណៈភាពនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០០ ហើយដូច្នេះបន្ទុកនៃកិចសន្យាចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៩ ត្រូវធ្លាក់មកលើអ្នកស្រី ធលដ ដូចការកំណត់នៃប្រកា ៤ នៃកិច្ចសន្យាខាងលើ ហើយអ្នកស្រី ធមលីនដា ក៏ជាសាក្សីម្នាក់ក្នុងកតិច្ចសន្យានេះដែរ ។

យល់ឃើញថា : ការដែលតំណាងចុងចម្លើយ ក៏ដូចជាមេធាវីរបស់ឈ្មោះ នេះដែរ ដែលលើកឡើងថា រឿងខ្ចីប្រាក់នេះមានការពាក់ពន្ធ័ដល់ឈ្មោះណា វ៉ាន់នីហើយតម្រូវឲ្យតុលាការបញ្ចូលឈ្មោះនេះមកក្នុងរឿងក្តីនេះជាតតិយ

ជននោះ តុលាការកំពូល ពុំអាចពិចារណាបានទេ ពីព្រោះក្នុងកិច្ចសន្យាទាំងពីរចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៩ ពុំមានប្រការណា ឬ តាវកាលិកណាមួយជាប់ពាក់ព័ន្ធនឹងឈ្មោះ ណាវ៉ាន់នីនេះទេ ។

យល់ឃើញថា ពុំមានភស្តុតាងណាបញ្ជាក់ជាកិច្ចសន្យាទាំងពីរចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៩ ដែលជាកម្មវត្ថុនៃការប្ដឹងឱ្យអនុវត្តនេះមានភាពមិនប្រក្រតី ដែលអាចទុកជាមោឃៈបានទេ ដូច្នេះគូភាគីនៃកិច្ចសន្យានេះ ត្រូវបំពេញកាតព្វកិច្ចតាមការកំណត់នៃមាត្រា ២៩ នៃព្រឹត្យ-ច្បាប់ស្ដីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅ កិច្ចសន្យា ។

យល់ឃើញថាៈ ដើមចោទពុំបានមកចូលរួមសវនាការនេះទេ ប៉ុន្តែមេធាវីរបស់ដើមចោទបានមកចូល រួមហើយ ដូច្នេះ តុលាការកំពូល ជំនុំជំរះ កំបាំងមុខដើមចោទប៉ុន្តែចាត់ទុកជាចំពោះមុខ ។

យល់ឃើញថាៈ សាលដីការដ្ឋប្បវេណីលេខ ២៣ (ឃ) ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្ដីចំពោះមុខចុងចម្លើយកំបាំងមុខដើមចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១- ទទួលបណ្ដឹងសាទុក្ខលេខៈ ២៤៣ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ របស់អ្នកស្រីធមលីនដា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ២៣(ឃ)ចុះថ្ងៃទី២៨ខែមេសា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដីដែលដើមចោទ បានបង់ជួសនៅតុលាការកំពូលចំនួន ១៩០០០៛ គឺៈ

- ពន្ធចុះបញ្ជីក្ដីនិងពន្ធហ្នឹងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០០៛ សម្រាប់ជារង្វាន់ ក្រឡាបញ្ជីកាន់ហិបប្រាក់,

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥០០០៛សរុប ១៩០០០៛ ។

ហើយតម្រូវឱ្យចុងចម្លើយសងប្រាក់ចំនួន ១៩០០០៛ នេះទៅដើមចោទវិញ ។

បង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រ១% លើទឹកប្រាក់ដែលត្រូវសងទៅដើមចោទ ។

៥-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៦ ។